ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតអបអរសាទរ

## សូមគោរពជូន
## ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយទឹកចិត្តសប្បាយរីករាយឥតឧបមាក្នុងឱកាសដែល **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត** ត្រូវបាន **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជប្រទានគោរមងារជា "**កិត្តិទេសាភិបាលបណ្ឌិត**" ដែលជាគោរមងារកិត្តិយសពិសេសដ៏ឧត្តុង្គឧត្តមបំផុត នៃរាជបណ្ឌិត្យសភាកម្ពុជា ជូន **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** តែមួយរូបគត់។

ការទទួលបានគោរមងារ "**កិត្តិទេសាភិបាលបណ្ឌិត**" នេះពិតជាស័ក្តិសមនឹង គុណធម៌ សមត្ថភាព ស្នាដៃ និងការលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីយ៉ាងធំធេង មិនអាចកាត់ថ្លៃបានរបស់ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត** ក្នុងបុព្វហេតុជាតិមាតុភូមិ និងប្រជាជនកម្ពុជាប្រកបដោយទឹកចិត្តស្មោះសរ ព្រមទាំងបានចូលរួមចំណែកពុះពារនាពេលកន្លងមក រួមទាំងបច្ចុប្បន្ន ក្នុងការកសាងអភិវឌ្ឍប្រទេស និងការពារសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសង្គម និងវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីភាពរីកចម្រើន សុភមង្គល និងភាពសុខដុមរមនារបស់ប្រជាជាតិទាំងមូល។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយថែរក្សា ការពារ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត** និង **លោកជំទាវ** ព្រមទាំង **បុត្រា បុត្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ និងជ័យជម្នះក្នុងការបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅមុខប្រកបដោយការរីកចម្រើនលើគ្រប់វិស័យក្រោមដំបូលសុខសន្តិភាព និងប្រកបដោយភាតរភាពនៃប្រជាជាតិខ្មែរទាំងមូល។

សូម **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ញឹម សុខា